ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ៦៥៣/១៦-១២-២០០៨

**សាលដីកា**

លេខ៨៩«ង» /០៣-៩-២០១០

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី០៣-៩-២០១០ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

**លោក** [redacted] **ប្រធាន**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**លោកស្រី** [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៦៥៣/១៦-១២-២០០៨រវាង៖

**-ជនជាប់ចោទឈ្មោះ** [redacted] **ច្វារាំង ហៅ** [redacted] **ថរះ(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ[redacted] ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ [redacted] ឪពុកឈ្មោះ[redacted] (រ)ម្តាយឈ្មោះ[redacted](រ)ប្រពន្ធឈ្មោះ[redacted] ហៅ វី។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី២០-០២-២០០៨។ម១។

ត្រូវចោទពីបទ«ប្លន់»ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-០១-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted]**(ចុងបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះ[redacted]។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-១១-២០០៨របស់ឈ្មោះ[redacted] ច្វារាំង មិនសុខចិត្ត

នឹងសាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចសេចក្តីសំរេចទាំងមូល។

**ឯដំណើររឿងមានដូចតទៅ៖**

តាមពាក្យបណ្តឹងចុះថ្ងៃទី២៩-០១-២០០៨របស់ឈ្មោះ[redacted] សំនៀងបានប្តឹងពីជនល្មើស៦នាក់ មិនស្គាល់ឈ្មោះបានប្លន់ទូរស័ព្ទដៃខ្លួនចំនួន២គ្រឿង ម៉ាកស៊ូនីអេរិកសាន់ ពណ៌ខ្មៅS500i និងម៉ាកណូគា ១១១០ និង ខ្សែដៃ ចិញ្ចៀន នៅចំណុចស្ទូន់ច្បារនាគបាញ់ទឹក កាលពីថ្ងៃទី២៨-០១-២០០៨ វេលាម៉ោង២១ម៉១៥នាទី រួចពួកវាគេចខ្លួនបាត់។

**ឃ្មានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញ បានសំរេចសេចក្តីដូចតទៅ៖

១-ផ្តន្ទាទោសលើ៖

ក/ឈ្មោះ[redacted] វណ្ណា ហៅ ជ្រូក ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ (ប្រាំឆ្នាំគត់) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២០-០២-២០០៨។

ខ/ឈ្មោះ[redacted]បារាំង ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ (ប្រាំឆ្នាំគត់) គិតពីសាលក្រមមុនៗ។

គ/ ឈ្មោះ[redacted]ឌី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ (ប្រាំឆ្នាំគត់) គិតពីចាប់ខ្លួនបាន។

ពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-០១-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

២-ទុកឲ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងនៅពេលក្រោយ។

៣-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧-១០-២០០៨ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៩-១០-២០០៨ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]វណ្ណា ហៅ ជ្រូក ,[redacted] បារាំង កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ឌី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិឲ្យប្តឹងទាស់និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះថាច់បារាំង.

ក្រឡាបញ្ជីអានចំលើយដើមបណ្តឹងរដ្ឋប្បវេណី.

តំណាងមហាអយ្យការសន្និដ្ឋានថា៖មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted]បារាំង ពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-០១-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។សុំសំរេចតំកល់សាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។



៧៩៨

មេធាវី [redacted] ម៉ាច សន្និដ្ឋានថាៈខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] បារាំង។កូនក្តីខ្លួនបានឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះមែន តែឆក់មិនគ្នាទេ គឺឆក់តែម្នាក់ឯងប៉ុណ្ណោះ។សុំកែប្រែពីបទប្លន់ មកជាបទលួចវិញ។

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍លេខ៤៦២ចុះថ្ងៃទី០៦-១១-២០០៨របស់ឈ្មោះ [redacted] បារាំង ប្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២-តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] បារាំង បានឆ្លើយសារភាព នូវអំពើប្រព្រឹត្តរបស់ខ្លួនថា កាលពីថ្ងៃកើតហេតុ ខ្លួន និង បក្សពួកមានគ្នា៣នាក់ ពិតជាបានធ្វើសកម្មភាពយកកាំបិតតាំងតោគំរាមជនរងគ្រោះ យកបានទូរស័ព្ទបានចំនួន២គ្រឿងប្រាកដមែន។

៣-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] បារាំង ពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-០១-២០០៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

៤-សាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចមានលក្ខណៈត្រឹមត្រូវទុកជាបានការ។

ហេតុដូច្នេះ

**ទិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៤៦២ចុះថ្ងៃទី០៦-១១-២០០៨របស់ឈ្មោះ [redacted] បារាំង ទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់ តែបដិសេធចោលដោយផ្អុយនឹងគតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ១២៧ក្រ១/១៩-១០-២០០៨របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី០៣-៩-២០១០ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ជំពូក ជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខាសំរិទ្ធិ [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ថ្ងៃទី 05 ខែ ១២ ឆ្នាំ២០១៤

**បានឃើញ**

**អគ្គស្នងការសាលាឧទ្ធរណ៍**

**ក្រឡាបញ្ជី**

[redacted] [redacted]